Natural Prolongation and Adjacent States

The Court dismissed both arguments, however. With respect to the Libyan arguments, it held that: [W]hile the idea of the natural prolongation of the land territory defined, in general terms, the physical object or location of the rights of the coastal State, it would not necessarily be sufficient, or even appropriate, in itself to determine the precise extent of the rights of one State in relation to those of a neighbouring State (*Continental Shelf (Tunisia v Libyan Arab Jamahiriya)* (the *Tunisia/Libya* case) [1982] ICJ Rep 18, para.43).

The Court thus concluded that: The principle that the natural prolongation of the coastal State is a basis of its legal title to continental shelf rights does not in the present case, as explained above, necessarily provide criteria applicable to the delimitation of the areas appertaining to adjacent States (*Continental Shelf (Tunisia v Libyan Arab Jamahiriya)* (the *Tunisia/Libya* case) [1982] ICJ Rep 18, para.48).

តុលាការបានច្រានចោលនូវអំណះអំណាងទាំងពីរ។ ទាក់ទងនឹងអំណះអំណាងរបស់ប្រទេសលីប៊ី តុលាការបានយល់ឃើញថា "ជាទូទៅ ខណៈដែលគំនិតនៃពន្លយដោយធម្មជាតិនៃដែនដីត្រូវបានកំណត់ ទីតាំងរូបវន្ត ឬទីតាំងនៃសិទ្ធិរបស់រដ្ឋឆ្នេរសមុទ្រ មិនទាន់គ្រប់គ្រាន់ ឬសមស្របក្នុងការកំណត់ទំហំសិទ្ធិជាក់លាក់របស់រដ្ឋមួយ ធៀបនឹងរដ្ឋជិតខាងនោះទេ។

តុលាការបានសន្និដ្ឋានថា គោលការណ៍ "ពន្លយដោយធម្មជាតិនៃរដ្ឋឆ្នេរសមុទ្រដែលជាមូលដ្ឋាននៃសិទ្ធិស្របច្បាប់លើខ្ពង់រាបបាតសមុទ្រ (Continental Shelf) ដូចដែលបានពន្យល់ខាងលើ ក្នុងសំណុំរឿងនេះ មិនបានចែងលក្ខណវិនិច្ឆ័យអាចយកមកអនុវត្តចំពោះការកំណត់ព្រំដែនសមុទ្ររវាងរដ្ឋ ដែលនៅជាប់ខាងគ្នានោះទេ។

<u>**កំណត់សំគាល់**</u>៖ តុលាការទីនេះសំដៅ តុលាការយុត្តិធម៌អន្តរជាតិ។